ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ២៧៦.១....សហវ.ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០៩

# ប្រកាស
## ស្តីពីការផ្ទេរឥណទានថវិកា

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ , ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ , ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ , ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក, ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និង អនុក្រឹត្យលេខ ២០ អនក្រ.បក, ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និង កែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក, ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និង រដ្ឋាករ នាយកដ្ឋានពន្ធដារ និង រតនាគារជាតិនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២២៩ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីការផ្ទេរឥណទានថវិកា
- តាមការចាំបាច់ដើម្បីអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92. Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855-23-724 664 Fax: 855-23-427 798

# សម្រេច

**ប្រការ ១:** ត្រូវបានប្រតិបត្តិនៅក្នុងវង្វង់ថវិការបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ នូវការផ្ទេរឥណទានថវិកា ដូចមានបញ្ជាក់ក្នុងតារាងខាងក្រោមនេះ :

ឯកតា:លានរៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ច្បាប់ហិរញ្ញវត្ថុដើមឆ្នាំ | និយ័តកម្ម | | ឥណទានថ្មីក្រោយនិយ័តកម្ម |
|---|---|---|---|---|---|---|---|
| | | | | | កើន | ថយ | |
| | | | **និយ័តកម្មចេញ** | | | | |
| | | | **៩៩ - ចំណាយមិនទាន់បែងចែក** | | | 703.694 | |
| ៦៦ | | | បន្ទុកហិរញ្ញវត្ថុ (ការប្រាក់) | 120.000 | - | 120.000 | 0 |
| ៦៥ | | | ឧបត្ថម្ភកធនដល់រាជធានី-ខេត្ត និងឃុំ-សង្កាត់ | 253.544 | - | 253.544 | 0 |
| ០៩ | ០៩១ | | ចំណាយត្រៀមបំរុង | 360.878 | - | 180.150 | 180.728 |
| ១៦ | | | ការទូទាត់ប្រាក់ខ្ចី និង បំណុលប្រហាក់ប្រហែល | 150.000 | - | 150.000 | 0 |
| | | | **និយ័តកម្មចូល** | | | | |
| | | | **<u>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ</u>** | | 703.694 | | |
| ៦១ | ៦១៥ | ៦១៥៣ | ការថែទាំ និង ជួសជុលផ្លូវ ផ្លូវលំ ស្ពាន និង លូ | 0 | 150.150 | - | 150.150 |
| ៦៦ | | | បន្ទុកហិរញ្ញវត្ថុ (ការប្រាក់) | 0 | 120.000 | - | 120.000 |
| ៦៥ | ៦៥១ | ៦៥១១ | ឧបត្ថម្ភកធនដល់រាជធានី ខេត្ត | 0 | 111.120 | - | 111.120 |
| ៦៥ | ៦៥១ | ៦៥១៣ | ឧបត្ថម្ភកធនដល់ឃុំ សង្កាត់ | 0 | 142.424 | - | 142.424 |
| ៦៣ | ៧០៩ | | ការសង និង ការបង្វិលវិញ | 0 | 30.000 | - | 30.000 |
| ១៦ | | | ការទូទាត់ប្រាក់ខ្ចី និង បំណុលប្រហាក់ប្រហែល | 0 | 150.000 | - | 150.000 |

**ប្រការ ២:** ឥណទានថវិកាដែលបានផ្ទេរក្នុងប្រការ ១ ខាងលើនេះត្រូវបានអនុញ្ញាតអោយបំពេញបន្ថែមទៅក្នុងសៀវភៅថវិការបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ ។

**ប្រការ ៣:** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាអ្នកទទួលបន្ទុកអនុវត្តប្រកាសនេះ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

**ចម្លងជូន**

- អគ្គនាយកដ្ឋានរតនាគារជាតិ
- នាយកដ្ឋានពាក់ព័ន្ធ
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ